# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ២៤ ខែមីនា ឆ្នាំ២០១៧

## ជប៉ុនផ្តល់ថវិកាសរុបចំនួន ៣១៩,៤០៩ដុល្លារអាមេរិក សម្រាប់ការសាងសង់អគារសិក្សាថ្មីនៅ៤សាលា

ក្រោមគ្រោងការណ៍នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ជប៉ុន ជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (ជំនួយគូសាណូណិ) រដ្ឋាភិបាលជប៉ុន បានយល់ព្រមផ្តល់ថវិកាសរុបចំនួន **៣១៩,៤០៩ ដុល្លារអាមេរិក** ដើម្បីសាងសង់អគារសិក្សាថ្មី នៅក្នុងសហគមន៍ជនបទចំនួន ៤កន្លែង។ កិច្ចសន្យាផ្តល់ជំនួយ ត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ ដោយឯកឧត្តម ហូរីណូអ៊ុជិ ហ៊ីដេហ៊ីសា ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងអ្នកតំណាងស្ថាប័នទទួលជំនួយទាំងបួនសម្រាប់គម្រោងដូចតទៅ៖

**១. <u>គម្រោងសាងសង់អគារសិក្សាមួយខ្នង នៅអនុវិទ្យាល័យស្លាបលែង ក្នុងស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ (ថវិកាចំនួន៧៥,៤១៥ ដុល្លារអាមេរិក)</u>**

<u>អង្គភាពទទួលជំនួយ៖ មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ស្ពឺ</u>

គម្រោងនេះ នឹងសាងសង់អគារសិក្សាមួយខ្នង ដែលបំពាក់ទៅដោយបរិក្ខារសិក្សា នៅអនុវិទ្យាល័យស្លាបលែង ក្នុងខេត្តកំពង់ស្ពឺ។ ក្នុងនោះបង្គន់អនាម័យ ក៏នឹងត្រូវបានសាងសង់ជូនផងដែរ។ ជាមួយនឹងគម្រោងនេះ សិស្សានុសិស្សប្រមាណជា ១,១៣៩នាក់ នឹងអាចសិក្សានៅក្នុងបរិស្ថានអប់រំប្រកបដោយសុវត្ថិភាព និងផាសុខភាពជាងមុន។

**២. <u>គម្រោងសាងសង់អគារសិក្សាមួយខ្នង នៅអនុវិទ្យាល័យសម្តេចឪសម្តេចម៉ែ ក្នុងក្រុងបានលុង ខេត្តរតនគិរី (ថវិកាចំនួន ៨៣,000 ដុល្លារអាមេរិក)</u>**

<u>អង្គភាពទទួលជំនួយ៖ មន្ទីរអប់រំ យុវជន និងកីឡាខេត្តរតនគិរី</u>

គម្រោងនេះ នឹងសាងសង់អគារសិក្សាមួយខ្នង ដែលបំពាក់ទៅដោយបរិក្ខារសិក្សា នៅអនុវិទ្យាល័យសម្តេចឪសម្តេចម៉ែ ក្នុងខេត្តរតនគិរី។ ជាមួយនឹងគម្រោងនេះ សិស្សានុសិស្សប្រមាណជា ១,៨៣១នាក់ នឹងអាចសិក្សានៅក្នុងបរិស្ថានអប់រំប្រកបដោយសុវត្ថិភាព និងផាសុខភាពជាងមុន។

**៣. <u>គម្រោងសាងសង់អគារសិក្សាមួយខ្នង នៅសាលាបឋមសិក្សាយ៉ាដាវ ក្នុងស្រុកអូរយ៉ាដាវ ខេត្តរតនគិរី (ថវិកាចំនួន ៨០,៧៥០ ដុល្លារអាមេរិក)</u>**

<u>អង្គភាពទទួលជំនួយ៖ មន្ទីរអប់រំ យុវជន និងកីឡាខេត្តរតនគិរី</u>

គម្រោងនេះ នឹងសាងសង់អគារសិក្សាមួយខ្នង ដែលបំពាក់ទៅដោយបរិក្ខារសិក្សា នៅសាលាបឋមសិក្សាយ៉ាដាវ ក្នុងខេត្តរតនគិរី។ ក្នុងនោះបង្គន់អនាម័យ ក៏នឹងត្រូវធ្វើការសាងសង់ជូនផងដែរ។ ជាមួយនឹងគម្រោងនេះ សិស្សានុសិស្សប្រមាណជា ៦៧៧នាក់ នឹងអាចសិក្សានៅក្នុងបរិស្ថានអប់រំប្រកបដោយសុវត្ថិភាព និងផាសុខភាពជាងមុន។

### ៤. គម្រោងសាងសង់អគារសិក្សាមួយខ្នង នៅសាលាបឋមសិក្សាគគីរ ក្នុងស្រុកកៀនស្វាយ ខេត្តកណ្តាល (ថវិកាចំនួន ៨០,២៤៤ដុល្លារអាមេរិក)

អង្គភាពទទួលជំនួយ៖ មន្ទីរអប់រំ យុវជន និងកីឡាខេត្តកណ្តាល

គម្រោងនេះ នឹងសាងសង់អគារសិក្សាមួយខ្នង ដែលបំពាក់ទៅដោយបរិក្ខារសិក្សា នៅសាលាបឋមសិក្សាគគីរ ក្នុងខេត្តកណ្តាល។ ជាមួយនឹងគម្រោងនេះ សិស្សានុសិស្សប្រមាណជា ១,៣៥៦នាក់ នឹងអាចសិក្សានៅក្នុងបរិស្ថានអប់រំប្រកបដោយសុវត្ថិភាព និងផាសុខភាពជាងមុន។

*ជំនួយឥតសំណងគូសាណូណិរបស់ជប៉ុន* បានចាប់ផ្តើមនៅប្រទេសកម្ពុជានៅឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍ និងស្តាបនាប្រទេសឡើងវិញនៅតាមកម្រិតមូលដ្ឋាន។ គម្រោងជំនួយនេះ មានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា ភាពក្រីក្រ និងភាពអកុសល ដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការចិញ្ចឹមជីវិត និងសេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជាជួយជំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង៥៦លានដុល្លារអាមេរិកដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីអនុវត្តគម្រោងគូសាណូណិចំនួន៥៧១ គម្រោងនៅទូទាំងប្រទេសកម្ពុជា៕

---

*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*
*ទូរស័ព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០*
*អ៊ីមែល: eco.jpn@pp.mofa.go.jp*
*គេហទំព័រ: http://www.kh.emb-japan.go.jp*